# សេចក្តីជូនដំណឹង
# ស្តីពី
# ការទិញមូលបត្រកម្មសិទ្ធិមកវិញ របស់ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក តាមវិធីសាស្ត្រដេញថ្លៃ

**ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក** សូមជូនដំណឹងស្តីពីសេចក្តីសម្រេចកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២៣ ពាក់ព័ន្ធនឹងការអនុម័តលើការទិញមូលបត្រកម្មសិទ្ធិមកវិញ ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

**ក-គោលបំណងនៃការទិញមូលបត្រកម្មសិទ្ធិមកវិញ**

គោលបំណង ឬហេតុផលនៃការទិញមូលបត្រកម្មសិទ្ធិមកវិញ ត្រូវបានគេរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុន និងម្ចាស់ភាគហ៊ុនរបស់ខ្លួន ដោយសារតែអ្នកគ្រប់គ្រងមានអារម្មណ៍ថាភាគហ៊ុនរបស់ក្រុមហ៊ុនបច្ចុប្បន្នមានតម្លៃទាប។

**ខ-ផែនការនៃការទិញមូលបត្រកម្មសិទ្ធិមកវិញ**

១. ទឹកប្រាក់អតិបរមាសម្រាប់ការទិញមូលបត្រកម្មសិទ្ធិមកវិញ គឺ ៨១៧.៨០០.០០០ រៀល។

២. ចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវទិញមកវិញដោយផ្អែកលើតម្លៃភាគហ៊ុនបច្ចុប្បន្នត្រូវបានគេរំពឹងថានឹងមិនលើសពី ៤០៥.០០០ ភាគហ៊ុន (តម្លៃទីផ្សារ ២០២០ រៀល/ភាគហ៊ុន) ឬស្មើនឹងត្រឹមតែ ១០% ប៉ុណ្ណោះ នៃចំនួនដើមទុនដែលបានបង់ចូល។

៣. ប្រភេទ/ស៊េរីមូលបត្រកម្មសិទ្ធិដែលត្រូវទិញមកវិញ: ភាគហ៊ុនធម្មតា។

៤. រយៈពេលនៃការទិញមូលបត្រកម្មសិទ្ធិមកវិញនឹងត្រូវចាប់ផ្តើមពី ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ២០២៤ រហូត ថ្ងៃទី ៣១ខែ សីហា ឆ្នាំ២០២៤។

៥. វិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវទិញមកវិញ: តាមវិធីសាស្ត្រដេញថ្លៃ

៦. ឈ្មោះក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជើងសារមូលបត្រ: អ អេច ប៊ី ស៊ីឃ្យួរីធី ម.ក

**គ-ព័ត៌មានទូទៅរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

១. ប្រាក់ចំណេញរក្សាទុក និងសាច់ប្រាក់លើស (excess liquidity) របស់ PPSP គឺយោងតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញ/ធ្វើសវនកម្មគិតត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៣ ។

- ប្រាក់ចំណេញរក្សារទុកគឺ ៨៨.៣០៦.៧៨៥.០០០ រៀល។

- បំណុលដែលបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវសងក្នុងរយៈពេល ៣ ខែ គិតចាប់ពីកាលបរិច្ឆេទដែលចាប់ ផ្តើមទិញមូលបត្រកម្មសិទ្ធិមកវិញគឺ ១២.៩៤៦.៨០៧.០០០ រៀល។
- លទ្ធភាពក្នុងការសងបំណុលដែលបានរៀបរាប់ខាងលើ និង ប្រភពមូលនិធិដែលត្រូវយកមកដើម្បីទូទាត់បំណុលនេះ៖ គិតត្រឹមទី ៣១ ខែ ធ្នូ ឆ្នាំ២០២៣ សាច់ប្រាក់នៅក្នុងដៃគឺ ១៦.៩៤៩.៦៣៤.០០០រៀល ហើយសម្រាប់ឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន ក្រុមហ៊ុនត្រូវបានគេរំពឹងថានឹងកំពុងបង្កើតលំហូរសាច់ប្រាក់វិជ្ជមាន ។

២. ចំនួនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ ភាគហ៊ុនឡើងទៅ៖ ៨០០ រូប។

៣. ចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% មានចំនួន ៨ ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

**ឃ-ផលប៉ះពាល់បន្ទាប់ពីការទិញមូលបត្រកម្មសិទ្ធិមកវិញ**

ផលប៉ះពាល់ត្រូវបានគេរំពឹងថានឹងមានភាពវិជ្ជមានសម្រាប់ក្រុមហ៊ុន ប៉ុន្តែដោយសារតែលក្ខណៈនៃប្រតិបត្តិការបែបនេះ លទ្ធផលរបស់វានឹងត្រូវបានដឹងតែបន្ទាប់ពីការកើតឡើងនៃព្រឹត្តិការណ៍ និងនៅលើលក្ខខណ្ឌទីផ្សារដែលកំពុងមាន។

**ង-ការចាត់ចែងលើមូលបត្រកម្មសិទ្ធិដែលបានទិញមកវិញ**

(១) រក្សាភាគហ៊ុន PPSP ដែលត្រូវបានទិញជាភាគហ៊ុនរតនាគារ ដែលអាចជា៖

(ក) ចែកជាភាគលាភដល់ម្ចាស់ភាគហ៊ុន PPSP

(ខ) លក់ភាគហ៊ុននៅក្នុង ផ.ម.ក ក្នុងតម្លៃខ្ពស់

(២) រក្សាផ្នែកនៃភាគហ៊ុន PPSP ដែលត្រូវបានទិញជាភាគហ៊ុនរតនាគារ ហើយលុបចោលភាគហ៊ុនដែលនៅសល់របស់ PPSP ។

ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក សូមធានាថាព័ត៌មានដែលបានផ្តល់ជូនខាងលើនេះ គឺជាព័ត៌មានពិតប្រាកដ ពេញលេញ និងត្រឹមត្រូវទាំងស្រុង និងសូមសន្យាថានឹងទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយដែលផ្តល់ជូន ជាព័ត៌មានមិនពិត ក្លែងបន្លំ ឬនាំឱ្យយល់ខុស។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២៤

**ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក**

ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក
ROYAL GROUP PHNOM PENH SEZ PLC.
KINGDOM OF CAMBODIA

ROYAL GROUP PHNOM PENH SEZ PLC.
Royal Group Phnom Penh Special Economic Zone
National Road No.4, Khan Kambol, Phnom Penh, Cambodia
+855 92 729 798 sales@ppsez.com